FARMER NOTES

ព្រឹត្តិប័ត្រព័ត៌មានកសិករ

ឆ្នាំទី ៤ លេខ ៣៣ ខែកុម្ភៈ ឆ្នាំ ២០០៥

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute



# បច្ចេកទេសដាំដុះដំណាំសណ្តែកបាយ



សណ្តែកបាយជាដំណាំមួយដែលចាត់ថ្នាក់ក្នុងពពួកដំណាំសណ្តែក Leguminosea ។ សណ្តែកបាយមានពីរប្រភេទ គឺប្រភេទដែលមានសំបកផ្លែពណ៌ខ្មៅនៅពេលទុំ (*Vigna mungo* = black gram) និងប្រភេទដែលលមានសំបកផ្លែពណ៌ប្រផេះនៅពេលទុំ (*Vignaradiata* = mungbean) ។

សណ្តែកបាយមានសារប្រយោជន៍ច្រើនសំរាប់ធ្វើជាចំណីអាហាររបស់មនុស្ស និងជាប្រភពចំណូលដ៏សំខាន់។ សណ្តែកបាយជាដំណាំដែលអាចទាញយកអាសូតពីបរិយាកាសដោយខ្លួនឯង និងជួយបង្កើនជីជាតិដី។ ប្រជាកសិករនិយមដាំដំណាំនេះនៅក្រោយពេលប្រមូលផលស្រូវរួច ជាពិសេសគេអាចដាំដុះវានៅតាមតំបន់មាត់ទន្លេ និងតំបន់ខ្ពង់រាប។ ផ្ទៃដីដាំដុះសណ្តែកបាយសរុបនៅប្រទេសកម្ពុជាគឺ ៤៤.៩៤០ហ.ត ដែលក្នុងនោះនៅរដូវវស្សាមានផ្ទៃដីដាំដុះ ៣៣.០១០ហ.ត និងរដូវប្រាំង ១១.៩៣០ហ.ត។ ទិន្នផល មធ្យមប្រចាំឆ្នាំគឺ ០,៧៣៤ត/ហ.ត (រដូវវស្សា ០,៧៤៤ត/ហ.ត រីឯរដូវប្រាំង ០,៧០៥ត/ហ.ត) *(ស្ថិតិកសិកម្ម ២០០៣-២០០៤ របស់ការិយាល័យស្ថិតិនៃ នាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)* ។

## ១. ការជ្រើសរើសទីកន្លែង និងការរៀបចំដី

ដំណាំសណ្តែកបាយអាចដុះលូតលាស់លើដីជាច្រើនប្រភេទ តែប្រជាកសិករខ្មែរនិយមដាំដំណាំនេះនៅលើដីតាមតំបន់ខ្ពង់រាប (ឡាបានសៀក និងកំពង់សៀម) និងតំបន់តាមមាត់ទន្លេ (ដីក្បៀនស្វាយ)។ ការរៀបចំដីមានសារសំខាន់ណាស់ដើម្បីឱ្យដីមានលក្ខណៈសមស្របឱ្យដំណាំអាចដុះលូតលាស់បានល្អ។ ឧបករណ៍ និងវិធីសាស្ត្ររៀបចំដីអាចមានលក្ខណៈខុសប្លែកពីគ្នាដោយយោងទៅតាមតំបន់ដាំដុះ រដូវកាលដាំដុះ ប្រភេទដី ឬលទ្ធភាពជាក់ស្តែងរបស់កសិករ។ ការភ្ជួររាស់ដីបានល្អ និងនាំឱ្យទិន្នផលកើនឡើងខ្ពស់។ យោងទៅតាមរដូវកាល និងតំបន់ដាំដុះ គេអាចអនុវត្តការរៀបចំដីដូចខាងក្រោម :

- តំបន់ខ្ពង់រាប (ក្រុមដីឡាបានសៀក និងកំពង់សៀម): គេភ្ជួរដីពីរលើក ដោយភ្ជួរលើកទីមួយរយៈពេលមួយខែមុនដាំនៅជំរៅ ២០ស.ម លើកទីពីរគឺភ្ជួរនៅមុនពេលរៀបចំដាំតែម្តង ជាទូទៅច្រើនតែបន្ទាប់ពីមានភ្លៀងធ្លាក់គ្រប់គ្រាន់ដែលបរិមាណសំណើមក្នុងដីអាចឱ្យដំណាំលូតលាស់បាន។ បន្ទាប់ពីភ្ជួរលើកទី២ ហើយគេហាលដីចោលមួយថ្ងៃរួចរាស់បំបែកដីឱ្យបានម៉ត់គួរសម បន្ទាប់មកទៀតទើបគេធ្វើការដាំដុះតែម្តង។
- តំបន់ទន្លេ (ក្រុមដីក្បៀនស្វាយ) :ការភ្ជួររាស់អាចប្រព្រឹត្តិទៅមួយដង ឬពីរដង អាស្រ័យទៅតាមសំណើមដីច្រើន ឬតិច។ ចំពោះការដាំនៅរដូវសំរក ការទុកចន្លោះពេលហាលដីចោល ៧ ទៅ ១០ថ្ងៃ បន្ទាប់ពីភ្ជួរលើកទី១ គឺជាការសមស្របដែលអាចជៀសវាងការបាត់បង់សំណើមដី។

## ២. ការជ្រើសរើសពូជ និងការរៀបចំគ្រាប់មុនដាំ

ត្រូវជ្រើសរើសពូជសសណ្តែកបាយណាដែលធន់ទ្រាំទៅនឹងជំងឺ សត្វល្អិត និងមានទិន្នផលខ្ពស់ ចំណែកគ្រាប់ពូជដែលយកមកដាំត្រូវមានអត្រាដំណុះខ្ពស់ និងជាគ្រាប់ពូជសុទ្ធល្អផងដែរ។ ចំពោះដីដែលខ្វះជាតិអាសូត គេត្រូវប្រឡាក់គ្រាប់ជាមួយម្សៅ Rhizobium ដើម្បីជួយជំរុញដល់ការចាប់យកអាសូត។ មុនពេលដាំយើងត្រូវជ្រើសរើសគ្រាប់ឱ្យបានល្អ ជៀសវាងការបំផ្លាញពីសត្វល្អិតចង្រៃ និងជម្ងឺ។ ការដាំជាជួរត្រូវការគ្រាប់ ១៥-២០គក/ហត ចំណែកឯការដាំដោយបាចគ្រាប់គេត្រូវការគ្រាប់ ៣០-៤០គ.ក/ហ.ត។

## ៣. វិធីសាស្ត្រដាំដុះ

**រដូវកាលដាំដុះ:** នៅតំបន់ខ្ពង់រាបគេនិយមដាំនៅដើមរដូវវស្សាតែមួយដងប៉ុណ្ណោះ គឺចាប់ពីដើមខែមេសាដល់ដើមខែឧសភា ហើយប្រមូលផលនៅចុងខែមិថុនាដល់ដើមខែកក្កដា បន្ទាប់ពីនោះគេដាំសណ្តែកសៀង។ ចំណែកឯតំបន់មាត់ទន្លេវិញគេអាចដាំជាពីរដំណាក់កាល គឺលើកទីមួយនៅខែកក្កដា-សីហា និងលើកទីពីរចាប់ពី ខែវិច្ឆិកា-ធ្នូ។

**អត្រាគ្រាប់ និងចន្លោះឃ្លាត:** សំរាប់ការដាំជាជួរគេទុកចន្លោះជួរប្រវែង ៥០-៦០ស.ម ចន្លោះគុម្ព ១០-២០ស.ម ឬ ២៥ស.ម និងដាំជំរៅពី ២-៥ស.ម ដោយដាក់គ្រាប់ ចំនួន ៤-៥គ្រាប់ ក្នុងមួយរណ្តៅ។

## ៤. ការប្រើប្រាស់ជី

ការប្រើប្រាស់ជីលើដំណាំសណ្តែកបាយគឺអាស្រ័យទៅតាមប្រភេទដី។ ចំពោះដីខ្សាច់ (ដីព្រៃខ្មែរ ដីប្រទះឡាង) ប្រើប្រាស់ជីអ៊ុយរ៉េ ១២៤គ.ក ជី DAP ៩៥គ.ក និងជី KCl ៣៧គ.ក ក្នុងមួយហិកតា។ ចំណែកដីល្បាប់ ឬឥដ្ឋ (ដីកំពង់សៀម ដីឡាបានសៀក ដីទួលសំរោង ដីកៀនស្វាយ) ប្រើប្រាស់ជីអ៊ុយរ៉េ ១៧៤គ.ក ជី DAP ១០៧គ.ក និងជី KCl ៤៥គ.ក ក្នុងមួយហិកតា។ ដោយប្រើប្រាស់ ១០០ភាគរយ នៃ P និង៥០ ភាគរយ នៃ N,K សំរាប់ទ្រាប់បាតពេលដាំ ចំណែក N,K ដែលនៅសល់ ៥០ភាគរយ ទៀតសំរាប់បំប៉នពេលពោតមានអាយុ ៣-៤សប្តាហ៍ *(ការិយាល័យវិទ្យាសាស្ត្រដី និងទឹក ២០០៤)*។

## ៥. ការថែទាំ



កូនដង្កូវ និងស្នាមបំផ្លាញ

**ការដករំលោះ:** ត្រូវដករំលោះកូននៅរយ:ពេល១៥ថ្ងៃ ក្រោយដាំដោយទុកតែ ២-៣ដើម/គុម្ពប៉ុណ្ណោះ ចំពោះចន្លោះគុម្ពធំជាង ២០ស.ម និងទុកតែមួយដើម ឬពីរដើម សំរាប់ចន្លោះគុម្ព ១០ស.ម។

**ការធ្វើស្មៅ:** ត្រូវធ្វើនៅរយ:ពេល ១៥ និង៣០ថ្ងៃ ក្រោយដាំ។ បើហួសពេលនេះវានាំឱ្យប៉ះពាល់ជាវិជ្ជមានដល់ប្រព័ន្ធឫស និងការកាន់ផ្កា ហើយម្យ៉ាងវិញទៀតដំណាំក៏ធំល្មមអាចប្រជែងនឹងស្មៅបាន។

## ៦. សត្វល្អិតចង្រៃ



ការរោមបំផ្លាញរបស់ចៃ

សត្វល្អិតដែលកើតលើដំណាំសណ្តែកបាយរួមមាន ដង្កូវរុយ ដង្កូវស្នែង ចៃសណ្តែក ពីងពាងក្រហម ដង្កូវកាត់ដើម ដង្កូវកាត់ស្លឹក ស្រើង រុយកូនសណ្តែក ដង្កូវស៊ីរូងកួរ ដង្កូវស៊ីផ្លែ។ល។ គេអាចកំចាត់សត្វល្អិតទាំងនេះដោយប្រើថ្នាំគីមីមួយចំនួន ឬប្រើវិធានការ IPM។

## ៧. ជំងឺ

ជំងឺសំខាន់ៗដែលកើតមានលើដំណាំសណ្តែកបាយមាន ជំងឺអុជត្នោត លើដំណាំសណ្តែក (Cercospora Leaf Spot) និងជំងឺរួញលឿងលើដំណាំសណ្តែកបាយ (Mungbean yellow mosaic virus) ក្រៅពីនេះមានជំងឺរលួយគល់ និងឫស (Root and basal stem rot) និងជំងឺរលួយខ្មៅ (Charcoal rot)។

## ៨. ការប្រមូលផល




ការបំផ្លាញដោយពួកដង្កូវ

សណ្តែកបាយចាប់ផ្តើមទុំនៅពេលមានអាយុពី ៥០ទៅ៧០ថ្ងៃ ក្រោយពេលដាំ។ នៅពេលទុំសំបកកួរប្រែពីពណ៌បៃតងទៅខ្មៅ ឬលឿងប្រផេះ សំបកកួរស្ងួតក្រៀមគ្រាប់ឡើងរឹងហើយភ្លឺរលោងនិងមានសំណើមគ្រាប់ប្រមាណ ២០ទៅ២៥ភាគរយ។ ចាប់ពីអាយុ ៧០ថ្ងៃ ឡើងទៅស្លឹកប្រែពណ៌លឿង និងក្រៀមជ្រុះតែម្តង។ ការប្រមូលផលអាចប្រព្រឹត្តិទៅច្រើនដងព្រោះវាទុំមិនស្រុះគ្នាទេ។

- លើកទី១: នៅពេលសណ្តែកទុំបានប្រមាណ ៥០ ទៅ៧០ភាគរយ។
- លើកទី២: នៅរយ:ពេល ១៥ថ្ងៃ ក្រោយប្រមូលលើកទីមួយ។
- លើកទី៣: រយ:ពេល ៧-១០ថ្ងៃ ក្រោយប្រមូលលើកទី ២។

☆ ការប្រមូលផលគួរធ្វើនៅពេលព្រឹក ព្រោះនៅពេលថ្ងៃរសៀលតែងមានអាកាសធាតុក្តៅនាំឱ្យងាយរបើកសំបកជ្រុះគ្រាប់។

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យក្សេត្រវិទ្យា និងប្រព័ន្ធកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា នៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ,

ទូរស័ព្ទលេខ: (៨៥៥-២៣) ៦៣១៩ ៦៩៣-៤ ទូរអក្ខរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh

SPheav@cardi.org.kh CPhaloeun@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh